២. ដាំបញ្ចូលនូវដំណាំប្រចាំឆ្នាំៈ រាល់រដូវដាំដុះ ជ្រើសរើសដំណាំណាដែលសមស្របនឹងលក្ខខណ្ឌពន្លឺថ្ងៃនិង ក៏រិតម្លប់ដែលកំពុងមាន។ ប្រភេទដែលធន់ទ្រាំនឹងម្លប់ហើយអាចដាំនៅស្រទាប់ក្រោមបានមានដូចជាៈម្ទាស់ ម្ទេស ត្រាវផ្អែម ល្ពៅ ផ្កា ដំឡូងជ្វា ត្រាវគោក ខ្ញី និងផ្សិត។

៣. ដាំបញ្ចូលនូវដំណាំដែលត្រូវការម្លប់ៈ បន្ទាប់ពីរយៈពេលមួយឆ្នាំឬនៅពេលដែលដើមឈើផ្តល់ម្លប់មានម្លប់គ្រប់គ្រាន់ គេត្រូវដាំបញ្ចូលនូវដំណាំដែលត្រូវការម្លប់។ ត្រូវដាំក្នុងគំលាត ៣-៤ ម ពីគ្នា និង ក្នុងប្រវែងពី ១-២ម ពីដើមឈើដែលផ្តល់ម្លប់។

៤. ដាក់ជី បោចស្មៅ និងកាត់មែក ប្រភេទឈើ (ដំណាំ) ផ្សេងៗទៀត។

៥. កាត់មែកប្រភេទឈើផ្តល់ម្លប់ៈ នៅពេលដែលប្រភេទនេះផ្តល់ម្លប់ច្រើនពេក ត្រូវកាត់មែកចេញខ្លះ ហើយប្រើប្រាស់កំទេចកំទីស្លឹកសំរាប់ធ្វើជាជីស្រស់។

៦. ធ្វើឱ្យរហាលៈ ត្រូវឧស្សាហ៍ពិនិត្យមើលដើមឈើដែលដុះក្បែរគ្នា នៅពេលដែលគំរបស្លឹកដុះប៉ះគ្នា ក៏ដូចជាប្រភេទដែលចូលចិត្តពន្លឺថ្ងៃ ដែលកំពុងគ្របដោយប្រភេទឈើដែលមិនសូវមានតំលៃ។ មួយម្តងៗ គេត្រូវកាប់ធ្វើឱ្យរហាលនូវដើមឈើដែលខ្សោយជាង ឬ មិនសូវមានតំលៃ ដើម្បីផ្តល់លំហដល់ដើមឈើដែលមានតំលៃ។ ត្រូវប្រុងប្រយ័ត្នដោយមិនត្រូវធ្វើឱ្យមានរបួសស្នាមដល់ដើមឈើដែលបន្សល់ទុក នៅពេលដែលកាប់ដកហូត។ ដើមឈើដែលបន្សល់ទុកនឹងដុះលូតលាស់លឿន។

៧. ដាំបញ្ចូលបន្ថែមនូវប្រភេទផ្សេងៗទៀតៈដាំបញ្ចូលបន្ថែមនូវប្រភេទដែលចូលចិត្តម្លប់សំរាប់ជាអាហារនិងលក់ដូរ។

**តារាងទី ១ៈ ឧទាហរណ៍នៃដំណាំចំរុះ**

| ទំហំដើមឈើ | ប្រភេទចូលចិត្តពន្លឺថ្ងៃ (ដាំមុន) | ប្រភេទចូលចិត្តម្លប់ពេលនៅតូច (អាចដាំជាក្រោយ) |
|---|---|---|
| ប្រភេទឈើដើមធំ ខ្ពស់ | ដើមច័ន្ទក្រឹស្នា ដើមទឹកដោះ ស្វាវ ដូង *Gmelina arborea* ស្វាយ ធ្នង់ ម៉ៃសាក់ | ដើមធុរេន មង្ឃុត សារ៉ៃម៉ាវ និងប្រភេទឈើសំណង់ជាច្រើនប្រភេទ |
| ប្រភេទរុក្ខជាតិដើមធំ-មធ្យម | ស្វាយចន្ទី ស្តៅ ដូងប្រេង ត្របែក ដើមឈើហូបផ្លែជាច្រើនប្រភេទ និង ប្រភេទឈើធ្វើអុសជាច្រើនប្រភេទ | ដើមស្លា ឫស្សី ក្រវាញ |
| ប្រភេទដើមមធ្យម-តូច | ល្ហុង ដំឡូងមី ចេក | កាហ្វេ ផ្គៅ ម្រេច កាកាវ កេសរកូល |
| ប្រភេទដើមតូច (ពពួកស្មៅ) | ស្រូវតំបន់ខ្ពស់ បន្លែច្រើនប្រភេទ | ប្រភេទបន្លែត្រូវការម្លប់និងដំណាំផ្សេងៗជាច្រើនប្រភេទ |

ប្រភពៈ *Kathleen et al 1999.*